# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ គាំទ្រព្រះរាជបន្ទូលព្រះអតីតព្រះមហាក្សត្រដែលសព្វព្រះទ័យឆ្លើយបំភ្លឺចំពោះមុខតុលាការកាត់ទោសខ្មែរក្រហម

web site: hoksavann.org

ថ្ងៃទី២៨ កក្កដា ២០០៦

ទន្ទឹមគ្នានឹងពេលដែលតុលាការកាត់ទោសខ្មែរក្រហមកំពុងដំណើរការទៅមុខ ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ព្រះអតីតព្រះមហាក្សត្រខ្មែរបានមានព្រះរាជបន្ទូលក្នុងព្រះរាជសារមួយ ដែលចុះផ្សាយក្នុងគេហទំព័ររបស់ព្រះអង្គថា ព្រះអង្គមិនខ្វះសេចក្តីក្លាហាន នឹងឆ្លើយបំភ្លឺចំពោះមុខតុលាការកាត់ទោខ្មែរក្រហមនោះទេ។ រាជវង្សានុវង្សរបស់ព្រះអង្គ គ្រួសាររបស់ព្រះអង្គ ព្រះអគ្គមហេសីរបស់ព្រះអង្គ ព្រមទាំងប្រជាពលរដ្ឋជាច្រើន ដែលគាំទ្រព្រះអង្គ ត្រូវក្រុមខ្មែរក្រហមធ្វើទារុណកម្មគាបសួរចម្លើយរួចហើយសម្លាប់ចោល ។ យើងសូមគាំទ្រនូវការសំរេចព្រះទ័យដ៏ថ្លៃថ្លាឧត្តុងឧត្តមនេះ ព្រោះពិតជាព្រះអង្គមានព្រះបំណង ចង់កំចាត់បង់នូវមន្ទិលសង្ស័យរបស់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាមតិអន្តរជាតិ អំពីការពាក់ព័ន្ធរបស់ព្រះអង្គជាមួយខ្មែរក្រហម ដូចជាព្រះអង្គស្រែកអំពាវនាវ តាមវិទ្យុប៉េកាំងឲ្យប្រជាពលរដ្ឋខ្មែររត់ចូលព្រៃម៉ាគី តាមពិតចូលជាមួយខ្មែរក្រហម ព្រះអង្គធ្វើជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ជាប្រធានរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលសមាជិកសុទ្ធតែខ្មែរក្រហម ។ នៅពេលដែលខ្មែរក្រហមមានជ័យជំនះ នៅថ្ងៃទី១៧មេសា១៩៧៥ ព្រះករុណាមិនទាន់យាងនិវត្តចូលភ្នំពេញភ្លាមទេ រង់ចាំឲ្យខ្មែរក្រហមបោសសំអាតឲ្យស្អាតជាមុនសិន ។ បោសសំអាតនោះ គឺដេញប្រជាជនពីទីក្រុងភ្នំពេញ និងពីទីក្រុងនៃខេត្តនានានៃរាជាណាចក្រកម្ពុជា ឲ្យចូលទៅកាន់ជនបទ ។ ទុក្ខវេទនារបស់ប្រជាពលរដ្ឋពេលនោះ គួរឲ្យរន្ធត់ណាស់ ខ្លះស្លាប់តាមផ្លូវ ព្រះសង្ឃព្រះពុទ្ធសាសនា ក៏ត្រូវនិមន្តចេញពីវត្តអារាម ដូចជាប្រជាពលរដ្ឋធម្មតា អង្គខ្លះទ្រាំមិនបានក៏សឹកតាមផ្លូវ ។ ចំណែកសម្តេចព្រះសង្ឃរាជហួត-តាត និងមន្ត្រីជាន់ខ្ពស់ដទៃទៀត ដែលជាមុខសញ្ញានៃការកំទេចរបស់ខ្មែរក្រហម បានត្រូវខ្មែរក្រហមធ្វើគត ។ ត្រង់នេះស្របនឹងពាក្យព្រមានរបស់ព្រះករុណាពីប៉េកាំង មុនខ្មែរក្រហមទទួលអំណាច

ជាស្ពាពរថា បើបងប្អូនកូនចៅណា មិនរត់ចូលកងរំដោះ (ខ្មែរក្រហម) ទេ ដល់ពួកគេមានជ័យជំនះ ពួកគេនឹងកំទេចចោល ។ ឥឡូវនេះ ដូចព្រះករុណាមានព្រះបន្ទូលពិតមែន ព្រោះព្រះករុណាជាប្រធានរណសិរ្សផង ជាប្រធានរដ្ឋាភិបាលផង ។ នៅស្ពាតអូឡាំពិកទីក្រុងភ្នំពេញ ខ្មែរក្រហមបានប្រជុំគ្នាសំរេចថា បិទមិនឲ្យមានផ្សារមិនឲ្យចាយប្រាក់ បិទសាលារៀន បិទសាសនា កំទេចរបបលន់-នល់ជាដើម ។ ការប្រកាសជាផ្លូវការនោះ ពុំមែនព្រះករុណាពុំដឹងនោះទេ តែពុំព្រះអង្គដែលជាប្រធានជំទាស់ឡើយ ។ បន្ទាប់ពីនោះមក ពួកខ្មែរក្រហមក៏ចាប់អនុវត្ត តាមផែនការរបស់ពួកគេដែលបានគ្រោងទុក មានចាប់ពួករដ្ឋការលន់-នល់ និងពួកទាហានយកទៅកាប់សម្លាប់ បាញ់ចោល ដោយបញ្ឆោតថាយកទៅទទួលសម្ដេចឪ ។ បន្ទាប់ពីយាងចូលភ្នំពេញ ព្រះករុណាសម្ដេចក៏នៅតែធ្វើព្រះប្រមុខរដ្ឋខ្មែរក្រហម រហូតដល់ខែមេសាឆ្នាំ១៩៧៦ ទើបលាឈប់ ។ ក្នុងរយៈពេលមួយឆ្នាំ ដែលនៅក្នុងអំណាចរបស់ព្រះអង្គជាព្រះប្រមុខរដ្ឋនោះ ខ្មែរក្រហមបានអនុវត្តការកាប់សម្លាប់ប្រជាពលរដ្ឋជាទូទៅ ចំពោះប្រជាពលរដ្ឋដែលខ្មែរក្រហមចោទថា ជាបញ្ញវ័ន្តអ្នកចេះដឹង ជាមូល-ធនអ្នកមានទ្រព្យពីរបបមុន ជាសក្តិភូមិប្រតិកិរិយា ឬមានកំហុសបន្តិចបន្តួច ត្រូវខ្មែរក្រហមចោទថា ជាខ្មាំងប្រឆាំងនឹងអង្គការបដិវត្តន៍ ក៏ត្រូវសម្លាប់ដែរ ។ សភាពការណ៍កើតលើងបែបនេះ តើព្រះករុណាមានព្រះតម្រិះដូចម្ដេចដែរ តើអាចយកពាក្យថា សូម្បីព្រះរាជវង្សានុវង្សរបស់ព្រះអង្គ ក៏ត្រូវខ្មែរក្រហមយកទៅកាប់សម្លាប់ដែរ យកមកធ្វើជាមូលដ្ឋាន ដើម្បីគេចវេះពីការទទួលខុសត្រូវរបស់ព្រះករុណាបានឬទេ ? ខ្មែរក្រហម បើគ្មានព្រះករុណា តើខ្មែរក្រហមយកជ័យជំនះលើប្រជាពល-រដ្ឋខ្មែរបានឬទេ ? មានសកម្មភាពពីរមានលក្ខណៈផ្ទុយគ្នា គឺរបបលន់-នល់បានដេញយៀកកុងនិងយួនខាងជើង ឲ្យចេញផុតពីទឹកដីខ្មែរ ចំណែកព្រះករុណាវិញបានពន្យះយៀកកុងនិងយួនខាងជើងទាំងនេះ ឲ្យចូលមកច្បាំងកាប់សម្លាប់ប្រជាពល-រដ្ឋខ្លួនវិញ -តើព្រះករុណាមានព្រះយោបល់ដូចម្ដេចដែរ ? ទ្រង់នរោត្តម-កន្តុលតំណាងព្រះរាជវង្សានុវង្ស និងលោកយែម-សំបូរតំណាងរដ្ឋសភា ដែលលោកលន់នល់ចាត់ទៅគាល់ព្រះករុណា ពេលនោះបើព្រះករុណាកុំមានៈព្រមទទួលជួបពិភា-ក្សាគ្នារវាងខ្មែរនិងខ្មែរ ឲ្យមានឯកភាពជាតិ តើថ្ងៃ១៨មីនាឆ្នាំ១៩៧០ ដែលចោទថាជារដ្ឋប្រហារនោះកើតមានឬទេ ? តាមការស្រាវជ្រាវជាប្រវត្តិសាស្ត្រ មុនថ្ងៃ១៨មីនានេះ គ្មានវរជនណា មានលោកលន់-នល់ជាដើម គ្មានបំណងអនុវត្តមធ្យោបាយនេះឡើយ តែដោយព្រះករុណាព្រះអង្គឯងបានជំរុញរឿងនេះឲ្យដល់ថ្នាក់នេះឯងដោយព្រះករុណាចោទអ្នកធ្វើបាតុកម្ម វាយប្រហារទូតយៀកកុងនិងយួនខាងជើងថាជាពួកក្បត់ ចង់បានដុល្លារអាមេរិកាំង រាជរដ្ឋាភិបាលស្រោចស្រង់ជាតិត្រូវតែទទួលខុសត្រូវ, ព្រះអង្គនឹងកំទេចអាស្រោចស្រង់ជាតិ ពេលដែលព្រះអង្គយាងត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ មានការព្រួយបារម្ភអំពី

ចារកិច្ចរបស់វៀតណាម នៅពាសពេញប្រទេសកម្ពុជាផង មានការភ័យភិតអំពីការគំរាមកំហែងរបស់ព្រះករុណាមកលើខ្លួនផង ក៏ស្នើទៅរដ្ឋសភាឲ្យបោះឆ្នោតទុកចិត្ត ឬដកសេចក្ដីទុកចិត្តលើព្រះប្រមុខរដ្ឋ ដែលហៅថារដ្ឋប្រហារនេះឯង ។ ដូច្នេះរឿងបន្តិចសោះមិនចេះសំរួលគ្នា កើតទៅជារឿងធំ ហើយការអាក់អន់ចិត្តនេះជារឿងផ្ទាល់ខ្លួន ទៅជារឿងជាតិទាំងមូល ។ តើចាត់ទុកថាជាអ្នកចាស់ទុំនយោបាយ ជាអ្នកដឹកនាំឈ្លាសវៃឬទេ ? ចាត់ទុកជាកំហឹងផ្ទាល់ខ្លួន ឬជាកំហឹងជាតិ ព្រោះប្រជាពលរដ្ឋខ្មែរគ្មានដឹងអ្វីទេ ។ ប្រជាពលរដ្ឋខ្មែរជាអ្នកស្លូតត្រង់ កាលមុនឆ្នាំ១៩៧០ ប្រជាពលរដ្ឋជឿគោរពព្រះករុណាជាព្រះប្រមុខរដ្ឋយ៉ាងខ្លាំងក្លា ប៉ុន្តែក្រោយឆ្នាំ១៩៧០ ប្រជាពលរដ្ឋពុំបានដឹងសោះថា ការអំពាវនាវឲ្យពួកគេព្រៃម៉ាគីនោះ ជាការឲ្យចូលធ្វើខ្មែរក្រហម ដែលជាឧក្រិដ្ឋជនសម្លាប់ខ្លួនវិញដូច្នេះឡើយ ។ ពេលខ្លះ ព្រះករុណាមានព្រះបន្ទូលហាក់ដូចជាបន្ទោសខ្មែរក្រហម ដើម្បីសំរាលការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមថា ព្រះករុណាស្មានថា ខ្មែរក្រហមជាបញ្ញវ័ន្តស្នេហាជាតិ ជាអ្នកស្អាតស្អំ មិនដឹងបើពួកគេស្រេកឃ្លានឈាមដូច្នេះឡើយ ។ ធ្វើនយោបាយ គេមិនត្រូវស្មានទេ គេមិនត្រូវធ្វើឲ្យជីវិតខ្មែរស្លាប់រាប់លាននាក់ ដោយនយោបាយស្មានទេ ។ មនុស្សម្នាក់ដែលគេជឿ បើនាំគេឲ្យដើរផ្លូវត្រូវ នោះនឹងនាំគេឲ្យបានសុខ តែបើនាំគេឲ្យដើរផ្លូវខុសវិញ នោះនឹងនាំគេឲ្យមានទុក្ខ ។ តួយ៉ាងដូចជាព្រះពុទ្ធដឹកនាំមនុស្សសត្វ ឲ្យបានសុខចេញចាកទុក្ខ គឺព្រះបរមសុខ ឬព្រះនិព្វានក៏ត្រូវ មធ្យោបាយទៅកាន់បរមសុខ គឺមគ្គប្រកបដោយអង្គប្រាំបីក៏ត្រូវ ។ ប្រៀបដូចអ្នកកាច់ចង្កូតនាវាឬរថយន្ត បើកាច់ចង្កូតខុសនឹងនាំឲ្យអ្នកជិះទាំងអស់ទទួលគ្រោះថ្នាក់ ។ ព្រះករុណាធ្វើនយោបាយស្មានទៀត គឺជួយយួនស្មានថាយួនដឹងគុណ ដូចកាលឆ្នាំ១៩៧៩ ពេលដែលយួនចូលឈ្លានពានប្រទេសកម្ពុជា ព្រះករុណាបានផ្ញើព្រះរាជសារលិខិតពទៅវៀតណាម វៀតណាមប្រមាថមើលងាយ ដោយមិនបើកមើល ហើយផ្ញើត្រឡប់មកវិញ ដោយពោលថា រឿងខ្មែរជារឿងមិនប្រែក្រឡាស់ ហើយសម្ដេចសីហនុក៏ត្រូវចប់ គឺគ្មានតួនាទីអ្វីទៀតទេ ។ ព្រះករុណាមានព្រះបន្ទូលដោយព្រះអង្គឯងថា ព្រះអង្គជួយយួនរហូតអស់ព្រះរាជបល្លង្ក គឺជួយយៀកកុង-យៀកណាមខាងជើង ឲ្យបោះទីតាំងនៅលើទឹកដីខ្មែរ រំលោភអព្យាក្រឹត្យរបស់ខ្លួន, ដឹកគ្រាប់បែកគ្រាប់កាំភ្លើងរបស់ចិនកុម្មុយនិស្ដ តាមកំពង់សោមទៅផ្ដល់ឲ្យយួន, ដឹកនាំអង្ករត្រីងៀតត្រីឆ្អើរឲ្យយួនស្ទើរពោយស្រុកខ្មែរ ។ លើសពីនេះទៅទៀត ពេលដែលហូ-ជីមិញស្លាប់ ដោយយកចិត្តយួនខ្លាំងពេកទៅ ព្រះករុណាបានយាងទៅប្រទេសវៀតណាម ដើម្បីថ្វាយបង្គំសពលោកហូ-ជីមិញ គឺក្នុងពិភពលោកមានតែព្រះប្រមុខរដ្ឋខ្មែរតែមួយព្រះអង្គគត់ ដែលទៅថ្វាយបង្គំសពលោកហូ-ជីមិញ ក្រោយមកនិមន្តព្រះសង្ឃសូត្រធម៌បង្សុកូលឧទ្ទិសកុសលឲ្យវិញ្ញាណក្ខន្ធហូ-ជីមិញនៅព្រះរាជវាំងក្រុងភ្នំពេញថែមទៀត ។ នៅពេលថ្មីៗនេះទៀត ព្រះករុណាព្រះមហាក្ស

ត្រថ្មីជាព្រះរាជបុត្រ នៅពេលដែលព្រះអង្គយាងទៅធ្វើ ព្រះរាជទស្សនកិច្ចនៅប្រទេសវៀតណាម ព្រះអង្គបានយកបាច់ផ្កាទៅគោរពរូបសំណាកលោកហូ-ជីមិញ ដែលជាអគ្គមគ្គុទ្ទេសក៍វៀតណាម ។ តើព្រះមហាក្សត្រខ្មែរធ្វើនេះ ដោយស្ម័គ្រព្រះទ័យដោយព្រះអង្គឯង ឬដោយការបង្ខិតបង្ខំពីវៀតណាម ។ តើថោកទាបយ៉ាងណាចំពោះព្រះមហាក្សត្រខ្មែរ ដែលតំណាងប្រទេស ទៅគោរពបូជាអគ្គមគ្គុទ្ទេសក៍គេដូចអគ្គមគ្គុទ្ទេសក៍របស់ខ្លួន ។ តើមានប្រមុខរដ្ឋណាទេ ពេលដែលទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាម ហើយគោរពរូបសំណាក់ហូ-ជីមិញ ដូចព្រះមហាក្សត្រខ្មែរឬទេ ? ការគោរពបែបនេះ សបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជាគ្មានប្រជាធិបតេយ្យខ្លួនឯងទេ គឺជាអាណានិគមនិយមរបស់វៀតណាមតាម ផែនការហូ-ជីមិញ គឺប្រទេសវៀតណាម ប្រទេសកម្ពុជា និងប្រទេសលាវ ជាសហព័ន្ធកុម្មុយនិស្ដតណ្ឋចិន ដែលមានប្រទេសវៀតណាមជាអ្នកដឹកនាំ ។ ព្រះករុណា មានព្រះបន្ទូលថា ព្រះអង្គមិនដែលចាញ់បោកអ្នកណាឡើយ អ្នកដែលបោកព្រះអង្គ នោះពុំទាន់កើតនៅឡើយ ដូច្នេះពាក្យថាព្រះអង្គជាប់គុករបស់ខ្មែរក្រហមនៅក្នុងវាំងនោះពុំមែនជាការពិតឡើយ ព្រះអង្គពុំចាញ់បោកខ្មែរក្រហមឲ្យដាក់គុកឡើយ ហើយព្រះអង្គប្រមូលខ្មែរ ឲ្យចូលព្រៃម៉ាគី ដែលខ្មែរក្រហមប្រមូលយកទៅធ្វើខ្មែរក្រហម ក៏ពុំចាញ់បោកខ្មែរក្រហមឡើយ ។ បើតាមន័យនេះ តើអំពើឧក្រិដ្ឋកម្មដ៏សាហាវរបស់ខ្មែរក្រហមកើតឡើងពីខ្មែរក្រហមខ្លួនឯងផ្ទាល់ ឬកើតឡើងពីគំនិតនរណា នៅពីក្រោយ ។ តើបានប្រយោជន៍អ្វីខ្លះ ក្រោយពីរបបសាធារណរដ្ឋខ្មែរលន់-នល់ និងចក្រពត្តិអាមេរិកាំងត្រូវចាញ់ របបខ្មែរក្រហមបានឡើងកាន់អំណាច ? លទ្ធផលគឺខ្មែរក្រហមបានកាប់សម្លាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់ បន្ទាប់មកវៀតណាមបានចូលមកឈ្លានពានប្រទេសកម្ពុជា ប្រមូលភោគទ្រព្យរបស់ខ្មែរ និងខ្មែរ ត្រូវស្លាប់ជាបន្តទៅទៀត ដូចជាផែនការក-៥ជាដើម ។ ដូច្នេះសង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ជាសង្គ្រាមស្នេហាជាតិ ឬជាសង្គ្រាមគំនុំសងសឹកដោយភាពល្ងង់ខ្លៅ ។ សង្គ្រាមកំពុងកើតមាននៅប្រទេសវៀតណាម អ្នកដឹកនាំខ្មែរនាំសង្គ្រាមមកដុតប្រទេសរបស់ខ្លួនឲ្យហិនហោចខ្ទេចខ្ទី ធ្វើឲ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនារកទីបំផុតគ្មាន ។ អ្នកដឹកនាំខ្មែរសប្បាយរីករាយណាស់នឹងសង្គ្រាមដើម្បីអំណាច នៅចំពោះមុខទឹកភ្នែកហូររហាមរបស់ប្រជាពលរដ្ឋខ្មែរអ្នកស្លូតត្រង់ ពន្យុះខ្មែរនិងខ្មែរឲ្យសម្លាប់គ្នា ដោយម្ខាងពឹងបរទេសឲ្យសម្លាប់ជាតិឯង ។ អ្នកដឹកនាំខ្មែរបានយកប្រយោជន៍ជាតិ មកបិទបាំងមហិច្ឆិតាផ្ទាល់ខ្លួន និងចោទបុគ្គលដែលប្រឆាំងនឹងខ្លួនថា គេក្បត់ជាតិ ដើម្បីឲ្យមានទម្ងន់យកគេទៅសម្លាប់ ដោយគ្មានឆ្លងតាមរយៈតុលាការយុត្តិធម៌និងឯករាជ្យឡើយ ។ បរទេសជិតខាងដែលតែងតែរំលោភយកទឹកដីខ្មែរ គេសប្បាយរីករាយដោយឃើញខ្មែរសម្លាប់គ្នាឯង ។ ប្រទេសជាមិត្តរបស់ព្រះករុណាលេខ១ គឺចិនកម្មុយនិស្ដ បន្ទាប់មកគឺកូរ៉េខាងជើង ហើយជាការធម្មតាគេហ៊ានថ្វាយវាំងបែបនេះ ដោ

យព្រះករុណាមានប្រយោជន៍ដល់គេ ដោយហោចណាស់តាមផ្លូវនយោបាយ ។
នៅឆ្នាំ១៩៩៣ អ៊ុនតាក់នៃអង្គការសហប្រជាជាតិ បានមករៀបចំសន្តិភាពឲ្យប្រទេសកម្ពុជា មានរៀបចំការបោះឆ្នោតជាដើម ផែនការរបស់គេមិនទាន់បញ្ចប់ផង ព្រះករុណាបានប្រកាសដេញអង្គការសហប្រជាជាតិ ថាគេធ្វើអាណានិគមនិយមលើខ្មែរ តាមការចាក់រុករបស់បក្សប្រជាជនកម្ពុជា ។ មុនការបោះឆ្នោត ព្រះករុណាបានណែនាំឲ្យទ្រង់រណឫទ្ធិរំលាយគណបក្សហ្វ៊ុនស៊ិនប៉ិច ហើយចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា តែទ្រង់រណឫទ្ធិពុំព្រម ។ ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ គណបក្សហ្វ៊ុនស៊ិនប៉ិចមានជ័យជំនះលើបក្សប្រជាជនកម្ពុជា ។ លទ្ធផលនេះបានធ្វើឲ្យគណបក្សប្រជាជនពុំសប្បាយចិត្ត ក៏បានបញ្ចុះបញ្ចូលព្រះករុណា ឲ្យធ្វើជានាយករដ្ឋមន្ត្រី ហើយឲ្យទ្រង់រណឫទ្ធិនិងលោកហ៊ុន-សែនធ្វើជាឧបនាយករដ្ឋមន្ត្រី តែសំណើនេះបានត្រូវទ្រង់រណឫទ្ធិបដិសេធប្រកាសបានតែ២៤ម៉ោងក៏ត្រូវរលាយ ។ បន្ទាប់មកទៀត គណបក្សប្រជាជនបានគំរាមបង្កើតអបគមន៍៧ខេត្ត ផ្នែកខាងកើតនៃប្រទេសកម្ពុជា តែការគំរាមនេះពុំបានសំរេចឡើយ ។ ព្រះករុណាបានតែងតាំងទ្រង់រណឫទ្ធិ ជានាយករដ្ឋមន្ត្រីទី១ លោកហ៊ុន-សែនជានាយករដ្ឋមន្ត្រីទី២ ដែលពុំដែលមានក្នុងពិភពលោក ដែលធ្វើឲ្យទ្រង់រណឫទ្ធិជាព្រះរាជបុត្រសំរេចអ្វីពុំកើត គឺសំរេចអ្វីមួយត្រូវមានការយល់ព្រមពីនាយករដ្ឋមន្ត្រីទាំងពីរ ឯប្រធានសភាខាងនីតិបញ្ញត្តិ បានទៅខាងគណបក្សប្រជាជនកម្ពុជា ។ ដូច្នេះអ្នកឈ្នះឆ្នោត បានត្រូវអ្នកចាញ់ឆ្នោតគាបទាំងខាងនីតិបញ្ញត្តិផង ទាំងខាងនីតិប្រតិបត្តិផង ដោយសារព្រះករុ-ណាជាព្រះបិតាបង្រួបបង្រួមៗ ធ្វើឲ្យអ្នកឈ្នះទៅជាអ្នកចាញ់ ឯអ្នកចាញ់ទៅជាអ្នកឈ្នះ ។ អង្គការសហប្រជាជាតិ គេមកជួយខ្មែរ ប្រាក់កាសគេចំណាយ គួរឲ្យគេនៅមួយឆ្នាំពីរឆ្នាំទៀតបន្ទាប់ពីបោះឆ្នោតរួច បើព្រឹត្តិការណ៍មិនសូវល្អ បើគណបក្សណារំលោភច្បាប់អង្គការសហប្រជាជាតិស្ថិតនៅទីនោះ គេនឹងបង្ក្រាប ។ តែគួរអនិច្ចាខ្មែរ ព្រះករុណាបានលូកព្រះហត្ថកកូរបញ្ហាខ្មែរសទៅជាខ្មៅ ខ្មៅទៅជាស ធ្វើឲ្យគណបក្សប្រជាជនដែលជាអ្នកចាញ់ មានជំហររឹងប៉ឹងកាន់តែខ្លាំងឡើង កីព្រះករុណាខាងណាខ្លាំង តែងតែអែបទៅខាងនោះ គឺយកតែរួចខ្លួនមួយពេលៗ ត្រង់ប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាយូរអង្វែងតទៅមុខទៀតបែបណានោះ ព្រះអង្គពុំយកព្រះទ័យទុកដាក់ឡើយ ។ ដូច្នេះបោះឆ្នោតលើកទី១នេះ ជំហររបស់ទ្រង់រណឫទ្ធិមានភាពត្រឹមត្រូវ ប៉ុន្តែត្រូវតែធ្វើតាមព្រះបិតាបង្រួបបង្រួមជាតិ ទោះបីទ្រង់មិនពេញចិត្តមធ្យោបាយរបស់ព្រះបិតាក៏ដោយ ។ ដូចព្រះករុណាបង្កើតរណសិរ្សរួបរួមជាតិ ឲ្យខ្មែរក្រហមឈ្នះជាដើម ។ ដោយមើលឃើញថា គណបក្សស្តេចបានអំណាចហើយមិនចេះប្រើ ទើបប្រជាពលរដ្ឋខ្មែរដកការទុកចិត្តបន្តិចម្តងៗ ពីគណបក្សហ្វ៊ុនស៊ិនប៉ិច ទើបលទ្ធផលនៃតំណាងរាស្ត្រកាន់តែចុះចំនួនជាលំដាប់ ។ មកដល់ពេលនេះ ស្ថាប័នព្រះមហាក្សត្រត្រូវស្ថិតនៅលើកណ្តាប់ដៃនៃគណបក្សប្រជាជន ដោយសារព្រះ

មហាក្សត្រខ្លួនឯង ហុចព្រះហត្ថឲ្យគេចង ។ ដូចការចុះសន្ធិសញ្ញាបំពេញបន្ថែមឲ្យស្របច្បាប់នូវសន្ធិសញ្ញាមិនស្របច្បាប់ឆ្នាំ១៩៨៥ គឺព្រះមហាក្សត្រត្រូវតែប្រថាប់ត្រា ទោះព្រះអង្គពុំសព្វព្រះទ័យក៏ដោយ ។ ក្រឡេកមើលពីក្រៅ ហាក់ដូចព្រះករុណានិងលោកហ៊ុន-សែននៃគណបក្សប្រជាជនបែកគ្នា ប៉ុន្តែពុំដូច្នេះទេ បើពិនិត្យឲ្យដល់ជំរៅ ព្រះបាទសម្តេចព្រះនរោត្តម-សីហមុនី បានតែងតាំងជាព្រះមហាក្សត្រខ្មែរ និងលោកហ៊ុន-សែនតែងតែបានតំណែងជានាយករដ្ឋមន្ត្រី ព្រោះឆ្លងតាមការព្រមព្រៀងគ្នាជាយូរឆ្នាំណាស់មកហើយ ។ រឿងខ្មែរខុសគេ បើមិនមានការនិយាយព្រមព្រៀងគ្នាជាមុនទេ ពុំអាចមានលទ្ធផលដូច្នេះឡើយ ។ គណបក្សណាក៏ដោយឲ្យតែធ្វើការជូនជាតិពិតប្រាកដ នឹងត្រូវបានទទួលការគាំទ្រពីប្រជាពលរដ្ឋ ប៉ុន្តែប្រជាពលរដ្ឋខ្មែរសព្វថ្ងៃនេះមានការព្រួយបារម្ភអំពីការបាត់បង់ទឹកដី ដែលកើតអំពីសន្ធិសញ្ញាបំពេញបន្ថែមនេះ ដែលជាល្បិចរបស់វៀតណាម និងអាណិកជនវៀតណាមជាច្រើនហូរចូលមកប្រទេសកម្ពុជា ដោយគ្មានការត្រួតពិនិត្យ ។

អំពីអដ្ឋិធាតុរបស់ប្រជាពលរដ្ឋខ្មែរ ដែលខ្មែរក្រហមសម្លាប់នៅតាមសារមន្ទីរទីក្រុងភ្នំពេញ និងនៅទីដទៃទៀត តាមព្រះសំណើរបស់ព្រះករុណា ត្រូវបូជាដើម្បីឲ្យព្រលឹងវិញ្ញាណរបស់អ្នកស្លាប់ទៅចាប់កំណើតតទៀត ឯប្រាក់ជាង៥៦លានដុល្លារត្រូវយកទៅជួយអ្នកក្រីក្រខ្មែរ ។ សូមធ្វើសំណូមពរព្រះករុណាវិញ សូមរក្សាទុកអដ្ឋិធាតុទាំងនោះមួយរយៈពេលទៀត ទំរាំកាត់ទោសខ្មែរក្រហមរួច ទើបសំរេចបូជាឬយ៉ាងណា ព្រោះអដ្ឋិធាតុទាំងនេះ ជាភស្តុតាងសំខាន់ណាស់ គេអាចយកទៅធ្វើកោសល្យវិច័យបាន ឯរូបថតឬវីដេអូ គេអាចថតបន្លំ និងពុំអាចធ្វើកោសល្យវិច័យបានឡើយ ។ តាមអភិធម្ម មនុស្សសត្វដែលស្លាប់ត្រូវចាប់បដិសន្ធិភ្លាម ឯអដ្ឋិធាតុនោះ ជាធាតុទឹក ដី ភ្លើង ខ្យល់ គ្មានវិញ្ញាណស្ថិតនៅឡើយ ។ ការកាត់ទោសនោះពុំមែនមានន័យថា ចងពៀរជាមួយខ្មែរក្រហមឡើយ ប៉ុន្តែត្រូវរកយុត្តិធម៌ជូនអ្នករងគ្រោះ តើអ្នកណាខ្លះទទួលខុសត្រូវក្នុងការសម្លាប់ប្រជាពលរដ្ឋខ្មែរ តើអ្នកណានៅពីក្រោយការសម្លាប់នេះ ? ការរកយុត្តិធម៌នេះ ជាការចាំបាច់បំផុត ព្រោះពុំមានស្លាប់មនុស្សម្នាក់ពីរនាក់ទេ គឺស្លាប់រាប់លាននាក់ ដែលមានផែនការគ្រោងទុកយ៉ាងជាក់លាក់ជាទ្រង់ទ្រាយធំ ទោះបីចំណាចថវិកាអស់ប៉ុន្មានក៏ដោយ ឯថវិការសំរាប់ចំណាយជូនប្រជាពលរដ្ឋក្រីក្រ គេចាត់ទុកផ្សេងដោយឡែកតាមបំណងអ្នកម្ចាស់អំណោយ ។

រឿងខ្មែរក្រហមប៉ុន្មាននាក់ ដែលមានមុខសញ្ញាត្រូវកាត់ទោស ហើយដែលមានវ័យចាស់ជរា មានខ្លះមានជម្ងឺ មានខ្លះស្លាប់ទៅហើយ យើងបានធ្វើសេចក្តីអំពាវនាវជាច្រើនដងហើយ ដោយសុំឲ្យគេប្រមូលខ្មែរក្រហមទាំងនោះ ដាក់មួយកន្លែងមានសុវត្ថិភាពហើយថែទាំសុខភាពឲ្យបានល្អ ជៀសវាងការស្លាប់មិនប្រក្រតី ដើម្បីបានឆ្លើយក្នុងតុលាការ ទោះបីតុលាការនោះ ពុំសង្ឃឹមថារកយុត្តិធម៌ជូនអ្នករងគ្រោះ

បានក៏ដោយ ព្រោះមានអ្នកជំទាស់មិនឲ្យបង្កើតតុលាការ ដូចចិនកុម្មុយនិស្តជាដើម អាចធ្វើឲ្យខ្មែរក្រហមទាំងនោះស្លាប់មិនប្រក្រតី ដូចការស្លាប់មិនប្រក្រតីរបស់ប៉ុលពត ដើម្បីកុំឲ្យឡើងឆ្លើយក្នុងតុលាការ ព្រោះខ្លាចប៉ះពាល់ដល់ពួកគេ ។ ក្នុងពេលនេះ យើសូមថ្វាយព្រះពរព្រះករុណាសម្តេចសីហនុ សូមមានព្រះជន្មវែងនិងសុខភាពល្អ ដើម្បីបានឆ្លើយបំភ្លឺក្នុងតុលាការ ។៚

❑ ❑

❑